**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៤៣០ សសរ.កសក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារផ្តល់សេវាព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧

- បានឃើញប្រកាសលេខ២៥៥ ប្រក.កសក.ប ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ៩ នៃប្រកាសលេខ១០៩ ប្រក.កសក.ប ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតក្រុមការងារផ្តល់សេវាព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. លោកបណ្ឌិត | **ម៉ៅ មិនា** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. លោក | ជា សុខុន | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. លោក | គង់ សំអឿន | អនុប្រធាននាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម | មន្ត្រីបច្ចេកទេស |
| ៤. លោក | អ៊ឹង សុភាព | អនុប្រធាននាយកដ្ឋានដំណាំឧស្សាហកម្មនៃអគ្គនាយកដ្ឋានកសិកម្ម | មន្ត្រីបច្ចេកទេស |
| ៥. លោក | គង់ ពិសិដ្ឋ | អនុប្រធាននាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម | មន្ត្រីបច្ចេកទេស |
| ៦. លោក | គុយ ភក្តី | អនុប្រធាននាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានកៅស៊ូ | មន្ត្រីបច្ចេកទេស |
| ៧. លោក | គួរ ផល្លី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូនៃអគ្គនាយកដ្ឋានកៅស៊ូ | មន្ត្រីបច្ចេកទេស |
| ៨. លោក | យី យូខេង | អនុប្រធាននាយកដ្ឋានផលិតកម្មសត្វនៃអគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ | មន្ត្រីបច្ចេកទេស |
| ៩. លោក | ពេជ្រ ប៉េដា | អនុប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈ បសុព្យាបាលនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | មន្ត្រីបច្ចេកទេស |
| ១០. លោក | ស៊ុ ហ្សុក្រា | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ នៃរដ្ឋបាលជលផល | មន្ត្រីបច្ចេកទេស |
| ១១. លោក | រស់ គន្ធី | ប្រធានការិយាល័យវារីវប្បកម្មទឹកសាបនៃរដ្ឋបាលជលផល | មន្ត្រីបច្ចេកទេស |
| ១២. លោក | ប៉ុល ចាន់ធី | ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មានវិទ្យា នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | មន្ត្រីបច្ចេកទេស |
| ១៣. លោក | ផុន រិណា | ប្រធានការិយាល័យគ្រប់គ្រងការកែច្នៃនៃនាយកដ្ឋាន កសិ-ឧស្សាហកម្ម | មន្ត្រីបច្ចេកទេស |
| ១៤. លោក | ហ៊ី ឌីម៉ូលី | អនុប្រធានការិយាល័យឧស្សាហកម្មនិងការប្រើប្រាស់ផល អនុផលព្រៃឈើនៃរដ្ឋបាលព្រៃឈើ | មន្ត្រីបច្ចេកទេស |
| ១៥. លោក | ប៉ាង ផានិត | អនុប្រធានការិយាល័យការពារសត្វព្រៃនិងជីវចម្រុះ នៃរដ្ឋបាលព្រៃឈើ | មន្ត្រីបច្ចេកទេស |
| ១៦. លោក | ថា សុភ័ក្រ | អនុប្រធានការិយាល័យនីតិកម្ម និងផ្សព្វផ្សាយច្បាប់កសិកម្ម នៃនាយកដ្ឋាននីតិកម្មកសិកម្ម | មន្ត្រីបច្ចេកទេស |
| ១៧. លោក | ហេង ជូឡុង | ប្រធានការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | មន្ត្រីសម្របសម្រួល |

១៨. លោក **នាង សុទ្ធា** អនុប្រធានការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម
នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីសម្របសម្រួល
១៩. លោកស្រី **ផល ផាន់នី** អនុប្រធានការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម
នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីសម្របសម្រួល
២០. លោកស្រី **ចាន់ ស្រីញ៉ក់** អនុប្រធានការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម
នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីសម្របសម្រួល
២១. លោក **គង់ ស៊ិន្ថា** អនុប្រធានការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម
នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីសម្របសម្រួល

**ប្រការ២.**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងឆ្លើយឆ្លងជាផ្លូវការជាមួយកសិករ និងអតិថិជនអំពីព័ត៌មានកសិកម្មពាក់ព័ន្ធនឹងជំនាញបច្ចេកទេសនីមួយៗ
- ឆ្លើយតប និងរកដំណោះស្រាយរាល់បញ្ហាប្រឈម ឬចម្ងល់របស់កសិករ និងអតិថិជនពាក់ព័ន្ធនឹងការងារកសិកម្មឱ្យបានទាន់ពេលវេលា
- មន្ត្រីសម្របសម្រួល៖ រក្សាទុកសារសម្លេងរបស់កសិករ និងអតិថិជនដែលបានទូរស័ព្ទចូល និងភ្ជាប់ទំនាក់ទំនងទៅមន្ត្រីបច្ចេកទេសដើម្បីឆ្លើយតប។ ធ្វើការទំនាក់ទំនងផ្ទាល់ជាមួយប្រធានអង្គភាពសាមីដើម្បីរកដំណោះស្រាយ នៅពេលមន្ត្រីបច្ចេកទេសអាក់ខានមិនអាចឆ្លើយតបក្នុងរយៈពេលពីរថ្ងៃ
- មន្ត្រីបច្ចេកទេស៖ ទទួលខុសត្រូវខ្ពស់ក្នុងការឆ្លើយតបរាល់បញ្ហា ឬចម្ងល់នានារបស់កសិករ និងអតិថិជន និងធ្វើការឆ្លើយតបវិញភ្លាមដោយមិនលើសរយៈពេលពីរថ្ងៃ។ តាមដានពីការវិវត្តន៍ជាសាកលនៃបញ្ហាការប្រែប្រួល អាកាសធាតុ កត្តាជំងឺនានា និងផលប៉ះពាល់មកលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីងាយស្រួលក្នុងការឆ្លើយតប។ ចូលរួមសហការផ្តល់ឯកសារបច្ចេកទេសកសិកម្មថ្មីៗមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដាក់ចូលក្នុងគេហទំព័រផ្សព្វផ្សាយកសិកម្មកម្ពុជា (www.khmeragri.info) និងបណ្តាញទំនាក់ទំនងសង្គម ជាប្រយោជន៍សម្រាប់ប្រើប្រាស់តាមតម្រូវការ ។

**ប្រការ៣.**

អនុប្រធាន មន្ត្រីបច្ចេកទេស និងមន្ត្រីសម្របសម្រួលនៃក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវដឹកនាំប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៤.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥.**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធានអង្គភាពពាក់ព័ន្ធ

ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ១០ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ